ខែតុលា ឆ្នាំ២០២២

# សៀវភៅកត់ចំណាំ សន្និសីទ ទូទៅ

**សូម ត្រៀមខ្លួន !**

មុនពេលសន្និសីទចាប់ផ្ដើម ប្អូនៗអាចរៀបចំខ្លួនដើម្បី ស្ដាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់ តាមរយៈការស្វែងរក វិវរណៈផ្ទាល់ខ្លួនរបស់ប្អូនៗបាន ។

- ◯ តើខ្ញុំបានចំណាយពេលវេលាសម្រាប់ការអធិស្ឋាន ផ្ទាល់ខ្លួនហើយឬនៅ ?
- ◯ តើខ្ញុំបានអានព្រះគម្ពីរដែរឬទេ ?

« ខ្ញុំសូមអញ្ជើញក្មួយៗឲ្យយកចិត្តទុកដាក់ស្ដាប់នូវរឿងបីយ៉ាងនៅក្នុងសន្និសីទនេះ ៖ សេចក្ដីពិតដ៏បរិសុទ្ធ គោលលទ្ធិនៃព្រះគ្រីស្ទដ៏បរិសុទ្ធ និងវិវរណៈដ៏បរិសុទ្ធ ។ . . . ខ្ញុំអាចធានាដល់ក្មួយៗបានថា អ្វីដែលក្មួយៗនឹងស្ដាប់ឮនៅថ្ងៃនេះ និងថ្ងៃស្អែក គឺជាសេចក្ដីពិតដ៏បរិសុទ្ធ » ។

*ប្រធាន រ័សុល អិម ណិលសុន*[១]

# សូមសួរ

« ជានិច្ចជាកាល វិវរណៈតែងតែមកជាការឆ្លើយតបទៅនឹងសំណួរមួយ » ។

*អែលឌើរ ដែហ្វ្រី អ័រ ហូឡិន*[២]

## បន្ទាប់មក សូមស្ដាប់

« វិវរណៈដ៏បរិសុទ្ធសម្រាប់សំណួរនៅក្នុងដួងចិត្តរបស់ក្មួយៗនឹងធ្វើឲ្យសន្និសីទនេះមានតម្លៃ និងមិនអាចបំភ្លេចបានឡើយ ។ ប្រសិនបើក្មួយៗមិនទាន់បានស្វែងរកការផ្ដល់ការងារបម្រើមកពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយក្មួយៗឲ្យស្ដាប់ឮអ្វីដែលព្រះអម្ចាស់ចង់ឲ្យក្មួយៗស្ដាប់ឮនៅអំឡុងពេលពីរថ្ងៃនេះទេ ខ្ញុំសូមអញ្ជើញក្មួយៗឲ្យធ្វើវាឥឡូវនេះ » ។

*ប្រធាន រ័សុល អិម ណិលសុន*[៣]

**តើថ្មីៗនេះអ្នកគិតអំពីអ្វី ?**

សូមគិតអំពីសំណួរ ឬកង្វល់ដែលអ្នកអាចមាន ។ អ្នកអាចសរសេរវាទុកនៅទីនេះ ហើយគិតពីវានៅពេលអ្នកស្ដាប់សន្និសីទ ។ ទោះបីជាអ្នកគ្មានសំណួរ ឬកង្វល់ជាក់លាក់ណាមួយនៅក្នុងគំនិតក៏ដោយ ក៏ព្រះអម្ចាស់នឹងជួយអ្នកឲ្យរកឃើញនូវរបៀបដើម្បីរៀនសូត្រ និងរីកចម្រើនដែរ កាលដែលអ្នកព្យាយាមខិតខំដើម្បីស្ដាប់ទ្រង់ ។

ទាំងនេះគឺជាឧទាហរណ៍មួយចំនួន និងកន្លែងដើម្បីសរសេរសំណួររបស់អ្នកផ្ទាល់ ៖



# សូមកត់ត្រាទុក !

សូមបង្ហាញទៅព្រះអម្ចាស់ថា អ្នកត្រៀមខ្លួនរួចជាស្រេចដើម្បីទទួល និងធ្វើតាមវិវរណៈ ដោយការផ្ដោតលើការស្ដាប់តាមព្រះវិញ្ញាណ និងការកត់ត្រាទុកពីអ្វីដែលអ្នកគិត និងមានអារម្មណ៍ ។ សូមកុំបារម្ភពីការកក់ត្រាទុកនូវរាល់រឿងតូចតាចដែលបានមានប្រសាសន៍នោះឡើយ ។ អ្នកតែងតែអាចត្រឡប់ទៅអាន ឬមើលសុន្ទរកថាទាំងនោះវិញនៅពេលក្រោយ។បានជានិច្ច ។

---

« មានការប្រៀបធៀបដ៏អស្ចារ្យមួយ [ សម្រាប់ការកត់ចំណាំ ] នៅក្នុងព្រះគម្ពីរមរមន ។ មានផ្ទាំងចំណារធំ ដែលបានកត់ត្រានូវប្រវត្តិសាស្ត្រនៃប្រជាជន ហើយផ្ទាំងចំណារតូច ដែលកត់ត្រានូវវិវរណៈ និងរឿងពិសិដ្ឋនានា ។ ប្រសិនបើបុគ្គលម្នាក់ស្ដាប់សុន្ទរកថាមួយ . . . ហើយកំពុងកត់ត្រាទុកនូវអ្វីដែលបុគ្គលម្នាក់ទៀតនិយាយ នោះមានន័យថា អ្នកកំពុងកត់ត្រានៅលើផ្ទាំងធំ—ប្រវត្តិនៃការប្រជុំហើយ ។ ប្រសិនបើអ្នកកំពុងកត់ត្រាពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនដែលអ្នកមានដោយសារព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកកំពុងបង្កើតផ្ទាំងតូចសម្រាប់ខ្លួនឯងផ្ទាល់ » ។

*អែលឌើរ ដេវីឌ អេ បែដណា*៤

អ្វីដែលពួកលោកបានបង្រៀន ៖

គំនិត និងចំណាប់អារម្មណ៍របស់ខ្ញុំ ៖

សូមស្ដាប់តាមព្រះវិញ្ញាណ ។ តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេច ?

« ប្រសិនបើអ្វីទាំងអស់ដែលយើងបានទទួល គឺត្រឹមតែជាអ្វីដែលគ្រូបង្ហាញ នោះយើងកំពុងតែបាត់នូវអ្វីដែលសំខាន់បំផុតហើយ » ។

*អែលឌើរ ដេវីឌ អេ បែដណា*៥

អ្វីដែលពួកលោកបានបង្រៀន ៖



**ពុំមានរបៀបកត់ត្រាណាមួយដែលខុសនោះទេ**

តើអ្នកពិបាកក្នុងការយកចិត្តទុកដាក់មែនទេ ? សូមសាកល្បងធ្វើឲ្យការកត់ត្រារបស់អ្នកមានលក្ខណៈផ្ទាល់ខ្លួន ។ សូមបន្ថែមឱ្យឧល អក្សរកែច្នៃ ឬរូបគំនូរខ្លះៗ ដើម្បីជួយអ្នកឲ្យចងចាំពីរឿងរ៉ាវ ពាក្យសម្ដីដកស្រង់ ឬការបំផុសគំនិតដែលមានន័យចំពោះអ្នក ។

ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។



គំនិត និងចំណាប់អារម្មណ៍របស់ខ្ញុំ ៖

**ផ្អាកសិន !**

តើអ្នកបានទទួលចម្លើយណាមួយចំពោះសំណួររបស់អ្នកហើយឬនៅមកទល់នឹងពេលនេះ ? ប្រសិនបើអ្នកបានទទួលហើយ សូមចំណាយពេលមួយសន្ទុះ ដើម្បីកត់ត្រាការណែនាំ និងការដឹកនាំដែលអ្នកបានទទួលនោះទុក ។

« ខ្ញុំសន្យាថា នៅពេលអ្នកស្ដាប់ឮសំឡេងនៃព្រះអម្ចាស់សម្រាប់អ្នកនៅក្នុងការបង្រៀននៃសន្និសីទទូទៅនេះ ហើយអនុវត្តតាមការបំផុសគំនិតទាំងនោះ នោះអ្នកនឹងទទួលអារម្មណ៍ពីការជះឥទ្ធិពលនៃស្ថានសួគ៌មកលើអ្នក ហើយជីវិតរបស់អ្នក និងជីវិតរបស់អស់អ្នកដែលនៅជុំវិញខ្លួនរបស់អ្នកនឹងបានទទួលពរជ័យ » ។

*អែលឌើរ នែល អិល អាន់ឌើរសិន*[៦]

« នៅក្នុងពាក្យទាំងពីរម៉ាត់នេះ—‹ ស្ដាប់ទ្រង់ ›—ព្រះប្រទាននូវលំនាំមួយសម្រាប់ភាពជោគជ័យ សុភមង្គល និងអំណរនៅក្នុងជីវិតនេះ ។ យើងត្រូវ *ស្ដាប់* ព្រះបន្ទូលរបស់ព្រះអម្ចាស់ *ប្រុងស្ដាប់* ព្រះបន្ទូលទាំងនោះ ហើយ *ផ្ចៀងស្ដាប់* នូវអ្វីដែលទ្រង់បានប្រាប់ដល់យើង ! »

*ប្រធាន រ័សុល អិម ណិលសុន*[៧]

អ្វីដែលពួកលោកបានបង្រៀន ៖

គំនិត និងចំណាប់អារម្មណ៍របស់ខ្ញុំ ៖

# ឥឡូវត្រូវធ្វើដូចម្ដេចទៀត?

នៅពេលសន្និសីទចប់ហើយ វាដល់ពេលដែលត្រូវអនុវត្តនូវអ្វីដែលអ្នកបាន ឮ និងទទួលអារម្មណ៍ពីសន្និសីទម្ដង ។ ទាំងនេះគឺជាសំណួរមួយចំនួនដើម្បី ជួយអ្នកឲ្យចាប់ផ្ដើម ៖

- ◯ តើមានអ្វីមួយដែលខ្ញុំអាចផ្ដោតទៅលើទេ កាលដែលខ្ញុំខំផ្ដោះទៅមុខនោះ ?
- ◯ តើមានអ្វីទាក់ទងទៅនឹងជីវិតរបស់ខ្ញុំ ដែលបានបំផុសគំនិតខ្ញុំឲ្យផ្លាស់ប្ដូរដែរឬទេ ?
- ◯ តើការបំផុសគំនិតអ្វីខ្លះដែលខ្ញុំនឹងធ្វើតាម ?
- ◯ តើខ្ញុំបានស្ដាប់ទ្រង់អំឡុងពេលសន្និសីទដោយរបៀបណា ?
- ◯ តើខ្ញុំអាចស្ដាប់ទ្រង់ឲ្យបានប្រសើរជាងនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្ញុំដោយរបៀបណា ?

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

តើអ្នករំភើបជាមួយនឹងរបៀបដែលកំណត់ត្រាសន្និសីទរបស់អ្នកដាក់ចូលគ្នាដែរឬទេ? តើអ្នកមានឌូឌល ឬរូបគំនូរខ្លះដែលអាចចែកចាយលើប្រព័ន្ធផ្សព្វផ្សាយសង្គមដែរឬទេ ? សូមចែកចាយវាជាមួយនឹងយើង ! សូមផ្ញើអ៊ីម៉ែលនូវរូបភាពនៃការកត់ត្រារបស់ប្អូនៗមកកាន់ ftsoy@ChurchofJesusChrist.org ឬ ចុះផ្សាយវានៅលើ Instagram ហើយដាក់ស្លាកគេហទំព័រ @strivetobe !

« ចម្លើយចំពោះការអធិស្ឋានដ៏ជាក់ច្បាស់ណាមួយរបស់ប្អូន។ ប្រហែលជាអាចមកដោយផ្ទាល់ពីសុន្ទរកថាណាមួយ ឬពីប្រយោគជាក់លាក់ណាមួយ ។ . . . បំណងប្រាថ្នាដ៏ស្មោះសរដើម្បីស្តាប់ និងធ្វើតាមពាក្យទូន្មានទាំងឡាយ នឹងរៀបចំផ្លូវសម្រាប់វិវរណៈផ្ទាល់ខ្លួន » ។

*អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ*[8]

ត្រូវការច្បាប់ចម្លងបន្ថែមទេ ?

សូមទាញយក និងបោះពុម្ពសៀវភៅកត់ចំណាំនេះពីគេហទំព័រ **conference.ChurchofJesusChrist.org** ។

**កំណត់ចំណាំ**

១. រ័សុល អិម ណិលសុន « Pure Truth, Pure Doctrine, and Pure Revelation » សន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០២១ ( *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០២១ ទំព័រ ៦ ) ។

២. ជែហ្វ្រី អ័រ ហូឡិន « Cast Not Away Therefore Your Confidence » *Ensign* ខែ មីនា ឆ្នាំ ២០០០ ទំព័រ ៩ ។

៣. រ័សុល អិម ណិលសុន « Pure Truth, Pure Doctrine, and Pure Revelation » ( ទំព័រ ៦–៧ ) ។

៤. ដេវីឌ អេ បែដណា « Create Your Own Small Plates » ( វីដេអូ ) នៅលើគេហទំព័រ ChurchofJesusChrist.org ។

៥. ដេវីឌ អេ បែដណា « Create Your Own Small Plates » ។

៦. នែល អិល អាន់ឌើរសិន សន្និសីទទូទៅ ខែ តុលា ឆ្នាំ ២០១៧ ( *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១២៦ ) ។

៧. រ័សុល អិម ណិលសុន « Hear Him » សន្និសីទទូទៅ ខែ មេសា ឆ្នាំ ២០២០ ( *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០២០ ទំព័រ ៨៩ ) ។

៨. ឌៀថើរ អេហ្វ អុជដូហ្វ « General Conference—No Ordinary Blessing » *Ensign* ឬ *Liahona* ខែ កញ្ញា ឆ្នាំ ២០១១ ទំព័រ ៤ ។

© 2022 by Intellectual Reserve, Inc. All rights reserved.

ការអនុញ្ញាតឲ្យបោះពុម្ពកូនសៀវភៅនេះឡើងវិញត្រូវបានអនុញ្ញាតឲ្យតែសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនប៉ុណ្ណោះ មិនមែនសម្រាប់ធ្វើពាណិជ្ជកម្មទេ ។ ការណ៍នេះរួមមានការអនុញ្ញាតឲ្យថ្នាក់ដឹកនាំវួដបោះពុម្ពច្បាប់ចម្លងចំនួនតិចតួច សម្រាប់អស់អ្នកដែលពួកគាត់បម្រើនៅក្នុងសមាសភាពនៃការហៅបម្រើរបស់ពួកគាត់ ។ កូនសៀវភៅនេះត្រូវតែបោះពុម្ពឲ្យបានគ្រប់ទំព័រ ។ ការណ៍នេះមិនរួមបញ្ចូលការអនុញ្ញាតឲ្យបង្ហោះតាមអ៊ីនធឺណិត ប្រើប្រាស់ក្នុងគោលបំណងថ្មី ឬចែកចាយសម្ភារនេះឡើយ ។ ការប្រើប្រាស់សម្ភារនេះលើសពីនេះណាមួយតម្រូវឲ្យមានការអនុញ្ញាតជាមុនសិន ។

**permissions.ChurchofJesusChrist.org**

សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ